# ភ្នំបាយ័ង (ភ្នំបាយ័ងកោរ)

ភ្នំបាយ័ងស្ថិតនៅក្នុងស្រុកគិរីវង់ ខេត្តតាកែវ ជាប់នឹងព្រំដែនវៀតណាមប្រហែល ២០គ.ម. និងមានចម្ងាយពីទីរួមខេត្តតាកែវប្រហែល៤០គ.ម.។ នៅលើកំពូលភ្នំដែលមានកម្ពស់ប្រហែល៣០០ម៉ែត្រនេះ គេបានសាងជាប្រាសាទដូចដែលយើងឃើញសព្វថ្ងៃនេះ។ គេសន្មតថាកំពូលភ្នំនេះជាស្ថានរបស់ទេព។

ប្រាសាទនេះមានឈ្មោះដើមថា "សិវបុរ" (ក្រុងរបស់ព្រះឥសូរ)។ ប្រាសាទនេះត្រូវបានសាងចាប់ពីស.វ.ទី៧ ពោលគឺចាប់ផ្ដើមសាងនៅក្នុងរាជ្យរបស់ព្រះបាទឦសានវរ្ម័នទី១ ដើម្បីឧទ្ទិសដល់ព្រះឥសូរ ហើយមានការបន្តសាងនៅរាជ្យស្ដេចក្រោយៗទៀតរហូតដល់ ស.វ.ទី១២។

ប្រាសាទនេះមានសិលាចារឹកច្រើនជាភាសាខ្មែរ និងសំស្ក្រឹត ដែលចាប់ផ្ដើមចារពី ស.វ.ទី៧ រហូតដល់ស.វ.ទី១២ ដែលមានលេខចុះបញ្ជីដូចជា K. 13, K. 14, K. 483, K. 850, K. 851, K. 852, K. 853, K. 854។ ខ្ញុំសូមសង្ខេបខ្លះៗទាក់ទងនឹងសិលាចារឹកខ្លះដូចខាងក្រោម។

សិលាចារឹកចុះបញ្ជីលេខ K. 13 និយាយអំពីការតម្កល់ "សិវបាទ" នៅលើកំពូលភ្នំដោយព្រាហ្មណ៍ម្នាក់ឈ្មោះ "វិទ្យាពិន្ទុ (Vidyābindu)" និងសាងស្រះទឹក២។ នេះប្រហែលជាគំនិតនៃការគោរពជំនឿលើ "សិវបាទ" ដោយរៀបរាប់អំពី "សិវបាទ" នៅហរិទ្វារដែលស្ថិតនៅភ្នំហេមពាន្ត[១]។

សិលាចារឹកចុះបញ្ជីលេខ K. 483 និយាយអំពីឈ្មោះ "ឧត្បន្នេស្វរ" (Utpannesvara) ដែលប្រហែលជាលិង្គតំណាងឱ្យអំណាចរបស់ព្រះឥសូរ។ K. 14 ចារនៅឆ្នាំ៨៧៨ ក្នុងរាជ្យរបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ និយាយថានៅក្នុងក្រុងសិវបុរ "ស្ដេចនៃកម្ពុជា" បានធ្វើអំណោយដល់ទេព។ ពាក្យ "កម្ពុជា" នេះប្រហែលជានិយាយលើកដំបូងនៅក្នុងសិលាចារឹកខ្មែរ។

សិលាចារឹកចុះបញ្ជីលេខ K. 850 ចារឹកនៅស.វ.ទី១២ ក្នុងរាជ្យរបស់ព្រះបាទធរណិន្ទ្រវរ្ម័នទី១ និយាយអំពីតង្វាយចំពោះប្រាសាទព្រះសិវបុរមានអង្ករសម្រាប់បុណ្យសង្ក្រាន្ត នារីគិនគ្រឿងក្រអូប បុរសជាអ្នកបម្រើបុណ្យសង្ក្រាន្ត ដោយបែងចែកការងារតាមវេនខ្នើត

---

[១] Bhattacharya 1964: 379-381

និងរនោច។

សិលាចារឹកចុះបញ្ជីលេខ K. 851 ចារឹកនៅសម័យមុនអង្គរស.វ.ទី៧ មានពីរបន្ទាត់ គឺ៖ ១- អាគ្នេយ៍ ២- ឱដៃមិណយេស្វាហា ជាពាក្យសូត្របួងសួងដល់មហាឥសី ដៃមិណី ដែលល្បីល្បាញខាងវិជ្ជាតារាសាស្ត្រ។

សិលាចារឹកចុះបញ្ជីលេខ K. 852 ចារឹកនៅឆ្នាំ១០២៩មហាសករាជ ត្រូវនឹងឆ្នាំ ១១០៧គ.ស. និយាយដល់កាលព្រះបាទធរណិន្ទ្រវរ្ម័នទី១ ឡើងសោយរាជ្យរួចហើយ ទ្រង់បានប្រតិស្ថាន ព្រះស្រីកទ្រេស្វរាស្រម នៅឯប្រាសាទ ព្រះសិវបុរ។ ទ្រង់បានថ្វាយព្រះ ជំនូនដល់ ព្រះស្រីកទ្រេស្វរាស្រម និងស្រុកស្រីកទ្រេស្វរាស្រម ជាមនុស្សបម្រើនៅទីនោះ ជាពីរក្រុមតាមវេនខ្នើតននិងរនោច ព្រមទាំងស្រែសម្រាប់ព្រាហ្មណ៍ជាស្មឹង ខែខ្នើត៥ ខែរនោច៥។

## ឯកសារយោង


Bhattacharya, Kamaleswar

1964. "Note sure le Śivapada." *Journal Asiatique*, pp. 379-381.

Cœdès, George

1937-66. *Inscriptions du Cambodge*. 8 volumes, EFEO, Paris.


អត្ថបទដោយ៖ លោក ញឹម សុធារិទ្ធ

# អត្ថបទ៖ភ្នំបាយ៉ង (ភ្នំបាយ៉ងកោរ)











n. 1106 / K. 851

K. 851 (យកចេញពី CISARK)

លោក ហ៊ុន ឈុនតេង ដែលជួយប្រែសម្រួលសិលាចារឹក

អត្ថបទដោយ៖ លោក ញឹម សុធារិទ្ធ